ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d'appui aux victimes**

ភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន
## ការបន្តធ្វើផែនការសម្រាប់ការស្នើសុំគម្រោងសំណងក្នុងសំណុំរឿង ០០២/០២

តាមរយៈការរៀបចំដោយជោគជ័យនូវកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធស្តីអំពីសំណងក្នុងសំណុំរឿង ០០២/០២ កាលពីខែមុន អង្គភាពគាំពារជនរងគ្រោះ និងអង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងរៀបចំ កិច្ចពិគ្រោះយោបល់មួយផ្សេងទៀត ជាមួយដើមបណ្តឹងរដ្ឋប្បវេណី អំពីសំណងក្នុងសំណុំរឿង ០០២/០២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១៤ ចាប់ពីម៉ោង៨ ព្រឹក ដល់ ៥ល្ងាច នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ ស្ថិតនៅក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ព្រឹត្តិការណ៍នេះនឹងមានការចូលរួមពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីប្រហែល ១០០ នាក់ ដែលមកពីបណ្តារាជធានី/ខេត្ត ក្នុងប្រទេសកម្ពុជា ដើម្បីពិភាក្សា និងបង្កើតសំណើគម្រោងសំណង សម្រាប់ករណីបន្ទាប់។ សម្រាប់អ្នកសារព័ត៌មាន សូមកត់សំគាល់ថា វគ្គដំបូង និងចុងក្រោយនៃកម្មវិធីត្រូវបានបើកសម្រាប់អ្នកសារព័ត៌មាន ប៉ុន្តែវគ្គផ្សេងៗទៀតទុកសម្រាប់តែអ្នកចូលរួមធម្មតាតែប៉ុណ្ណោះ។

ឧក្រិដ្ឋកម្មជាច្រើនដែលនឹងត្រូវរួមបញ្ចូលនៅក្នុងសវនការ ០០២/០២ ដែលរួមមាន៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ អង្គភាពគាំពារជន រងគ្រោះ និងអង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងស្វះស្វែងបង្កើតឲ្យមានសំណើផ្សេងៗ ពាក់ព័ន្ធទៅនឹងព្យសនកម្មដែលជាផលវិបាកនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងបង្កើតឲ្យមានសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី។

កន្លងមក អង្គភាពគាំពារជនរងគ្រោះ និងអង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏ធ្លាប់បានរៀបចំកិច្ចពិភាក្សាជាមួយ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីកំណត់ និងពិភាក្សាអំពីសំណើគម្រោងសំណងដែលមានសក្តានុពល សម្រាប់ជាប្រយោជន៍ដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម។

ដើមបណ្តឹងរដ្ឋប្បវេណី អាចទាមទារសំណងជាលក្ខណៈសមូហភាព និងផ្លូវចិត្តបាន។ គម្រោងសំណងគឺធ្វើ ឡើង ដោយសមស្របទៅតាមពិរុទ្ធភាពរបស់ជនជាប់ចោទ ដែលត្រូវបានគេសន្មតថាគ្មានទោសរហូតដល់ការប្រកាសសាលដីកាស្ថាពរនៃការជំនុំជម្រះក្តីចុងក្រោយ។

អង្គភាពគាំពារជនរងគ្រោះ ជាអង្គភាពផ្លូវការមួយរបស់ អ.វ.ត.ក ហើយមានភារកិច្ចសម្របសម្រួលឲ្យជនរងគ្រោះចូលរួមនៅក្នុងដំណើរការនីតិវិធី អ.វ.ត.ក។ លើសពីនេះ អង្គភាពគាំពារជនរងគ្រោះ ដោយសហការយ៉ាងជិតស្និទ្ធជាមួយ អង្គភាពសហមេធាវីនាំមុខ មានភារកិច្ចកំណត់ រៀបចំ និងអនុវត្តគម្រោងសំណង និង ស្វែងរកមូលនិធិ និងជំនួយជ្រោមជ្រែងដល់ការងារសំណង។


***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***

លោក នេត្រ ភក្ត្រា

មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម

ទូរស័ព្ទដៃលេខ៖ ៨៥៥ (0) ១២ ៤៨៨ ១៥៦

ទូរស័ព្ទលើតុលេខ៖ ៨៥៥ (0) ២៣ ៨៦១ ៥៦៤

សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh

| **ទំនាក់ទំនងអង្គភាពគាំពារជនរងគ្រោះ** |
| --- |
| **លោក** ឌី ឈុនសុង មន្ត្រីកម្មវិធីសំណង<br>**សារអេឡិចត្រូនិក៖** dy.chhunsong@eccc.gov.kh |